ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥០

ចុះថ្ងៃទី០១-៩-១៩៩៧

សាលដីកា

លេខ : ៣៣

ចុះថ្ងៃទី១១-៧-២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម ឃឹម បុណ្ណ ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រមរបាយការណ៍

៣- លោក សោម សិរីវឌ្ឍ ចៅក្រម

៤- លោក ជីវ កេង ចៅក្រម

៥- លោក ស៊ិន ឌឹម ចៅក្រម

លោក ឈាង វន្នា ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៧ របស់ឈ្មោះគីម អេង ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១៦៤ ចុះថ្ងៃទី១១-៦-១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៥០ ចុះថ្ងៃទី ០១ - ៩ - ១៩៩៧ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះគីម អេង " ម្ចាស់បណ្តឹងសាទុក្ខ " ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល របររកស៊ី នៅផ្ទះ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ១៩ ក្រុម៦ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ គុង យ៉ាំ " ស " ម្តាយឈ្មោះគីម អ៊ី " ស " ប្តីឈ្មោះសេក សុវណ្ណ មានកូន៤នាក់ នៅក្រៅឃុំ ទោសពីមុនគ្មាន ។

- មេធាវី គ្មាន

- ត្រូវចោទពីបទ : ឆបោកទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី២៥-៨-១៩៩៤ បទល្មើសដែលមានចែងតាមមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសុង រមន្នី " ចុងបណ្តឹងសាទុក្ខ " ភេទស្រី អាយុ៤៣ ជាតិខ្មែរ កើតនៅសង្កាត់ចាក់អង្រែក្រោម ក្រុងភ្នំពេញ របររកស៊ីលក់ដូរ មានទីលំនៅផ្ទះលេខ១៣៦៥ ក្រុម៦ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ-អ៊ី សុង " ស " ម្តាយឈ្មោះចេង តេ " រ " ប្តីឈ្មោះប៉េក ទ្យេ ។

- មេធាវី គ្មាន

- តាមពាក្យបណ្ដឹងចុះថ្ងៃទី២៥ - ០១ - ៩៦ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះសុង រមន្នី ចាន់ ណារី , ហោរ៉ា , ស៊ូ ថាច , ផាប ទូត , សុន ខុម និង គង់ ចន្ថា ប្ដឹងពីឈ្មោះគីម អេង ពីបទឆបោកលេងតុងទីន ដោយសំអាងហេតុថា ឈ្មោះគីម អេង បានធ្វើជាមេតុងទីន ហើយពួកខ្លួនបានចុះឈ្មោះធ្វើជាកូនតុងទីន សរុបទឹកប្រាក់ដែលឈ្មោះគីម អេង ជំពាក់ពួកខ្លួនមិនព្រមសងទាំង៧នាក់ គឺ៤៩០៨ ដុល្លារអាមេរិក និង ៦០ ម៉ឺនរៀល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអម តុលាការក្រុងភ្នំពេញសំរេចថា : ចោទប្រកាន់លើឈ្មោះគីម អេង ភេទស្រី អាយុ៦០ឆ្នាំ ពីបទ ឆបោកទ្រព្យសម្បត្តិអ្នកដទៃ កាលពីថ្ងៃទី២៥ - ៨ - ៩៤ តាមមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមលេខ ៣៤ "គ" ចុះថ្ងៃទី២៤ - ៧ - ៩៦ របស់តុលាការក្រុង - ភ្នំពេញ ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ :

១ - ផ្ដន្ទាទោសដាក់ពន្ធនាគារឈ្មោះ គីម អេង ចំនួនមួយឆ្នាំ តែទោសនេះត្រូវព្យួរក្នុងរយៈពេលសាកល្បង៥ឆ្នាំ គិតចាប់តាំងពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ពីបទ ឆបោកទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តកាលពីថ្ងៃទី២៥ - ៨ - ៩៤ នៅក្រុងភ្នំពេញ តាមបញ្ញត្តិមាត្រាទី៤៥ - ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - អោយឈ្មោះគីម អេង សងលុយអោយទៅឈ្មោះសុង រមន្នី ចំនួន៦៣០ដុល្លាអាមេរិក ឈ្មោះស៊ូ ថាច ចំនួន១៧០០ដុល្លាអាមេរិក ឈ្មោះផាប ទូន ចំនួន៦០០.០០០រៀល ឈ្មោះសុខ ខុម ចំនួន៦៥០ដុល្លាអាមេរិក ឈ្មោះគង់ ចន្ថា ចំនួន៦៣០ដុល្លាអាមេរិក ឈ្មោះចាន់ - ណារី ចំនួន៦៥០ដុល្លាអាមេរិក ឈ្មោះហោ រ៉ា ចំនួន៦៩០ ដុល្លាអាមេរិក វិញ ។

ករណីទីងទូលពុំព្រមសងត្រូវដាក់គុកបង្ខំដល់រូបកាយ និង រឹបអូសទ្រព្យសម្បត្តិឈ្មោះ គីម អេង លក់ឡាយឡុង ធានាសំណងតាមច្បាប់ស្ដីពីការដាក់គុក បង្ខំដល់រូបកាយ ក្នុងរឿង - ព្រហ្មទណ្ឌ ។

៣ - សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដីសំរេចបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៤៥ "គ" ចុះថ្ងៃទី០៧ - ៨ - ៩៦ របស់ឈ្មោះគីម អេង ដែលប្ដឹងពីសាលក្រមលេខ៣៤ "គ" ចុះថ្ងៃទី២៥ - ៧ - ៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា :

១ - ទទួលបណ្ដឹងឧទ្ធរណ៍លេខ៤៥ "គ" ចុះថ្ងៃទី០៧ - ៨ - ៩៦ របស់ឈ្មោះគីម អេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - ចាត់អង្កេតបន្ថែមលើរូបភាពតុងទីន ដើម្បីកំណត់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២៤ ចុះថ្ងៃទី១១ - ៦ - ៩៧ របស់សាលាឧទ្ធរណ៍

ដែលបានសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ - ៨ - ៨៦ របស់ជនជាប់ចោទ ឈ្មោះគីម អេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៣៤ " គ " ចុះថ្ងៃទី២៤ - ៧ - ៨៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី០៤ - ៨ - ៨៧ របស់ឈ្មោះគីម អេង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី១១ - ៦ - ៨៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ២២ - ៩ - ៨៧ របស់ឈ្មោះគីម អេង ធ្វើឡើងក្នុងកំណត់ច្បាប់។

- បានឃើញសារណាតប ចុះថ្ងៃទី២៥ - ៩ - ៨៧ របស់ឈ្មោះសុង រមន្នី ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអម តុលាការកំពូលថា :

- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះគីម អេង ឆបោក ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៥ - ៨ - ១៩៨៤ ពិតប្រាកដមែន ។

- តម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះគីម អេង ថា : បានជាខ្ញុំប្តឹងសាទុក្ខមកពីខ្ញុំសុំសង ១៣០០ដុល្លា និងសុំសងជាក់ខែដើមបណ្តឹងរដ្ឋប្បវេណីមិនយក ។

- បានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសុង រមន្នី ថា : ខ្លួនចង់អោយជនជាប់ចោទលក់ផ្ទះសងដោយមូលហេតុកូនជនជាប់ចោទ បានលេងតុងទីនជាមួយចំនួន៣នាក់ពេលដេញបាន ៤នាក់ដែរកូនរួចហើយប្រកាសរំលាយ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការសូមដំកល់សេចក្តីសន្និដ្ឋាននៅដដែល។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៨៧ របស់ឈ្មោះគីម អេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃ -

ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែលបានផ្តន្ទាទោស ឈ្មោះគីម អេង ពីបទឆបោកនោះគឺជាការភ័ន្តច្រឡំពីព្រោះការលេងតុងទីននេះគឺជាកិច្ចសន្យា មួយដែលឈ្មោះគីម អេង បានអនុវត្តជាហូរហែររហូតមកដល់១៣លើករួចហើយទើបតែមានបញ្ហានៅ លើកទី១៤ប៉ុណ្ណោះ ។ ហើយការដែលមិនបានប្រគល់ប្រាក់អោយអ្នកដេញបានទី១៤នេះ ពុំមានភស្តុតាង ណាបញ្ជាក់ថាឈ្មោះគីម អេង បានប្រមូលលុយរួចហើយ ប៉ុន្តែមានឧបាយកលទុច្ចរិតមិនយកទៅប្រគល់ អោយគេដែរ ។

- យល់ឃើញថា អង្គហេតុនៃរឿងនេះ គឺជារឿងកិច្ចសន្យាសុទ្ធសាធ ពុំមែនបទល្មើស ព្រហ្មទណ្ឌទេពីព្រោះឈ្មោះគីម អេង ពុំបានប្រើប្រាស់ឧបាយកលទុច្ចរិតទេដូច្នេះផ្អែកតាមមាត្រា២៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការកំពូលសំរេចជាមោឃៈដោយឥតបង្វិល ទុកអោយដើមបណ្តឹង រដ្ឋប្បវេណីប្តឹងទៅតុលាការរដ្ឋប្បវេណី ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

១ - ទទួលបណ្តឹងសាទុក្ខលេខ២៣២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៧ របស់ឈ្មោះគីម អេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១២៤ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ របស់ សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៣ - សាលដីកានេះជំនុំជំរះនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០១ ។